


អបអរសាទរទិវាបុណ្យជាតិ

# ម៉ាឡេស៊ី ខួបលើកទី ៦៣

## ការយកចិត្តទុកដាក់របស់ម៉ាឡេស៊ី

របាយការណ៍ពិសេស

ថ្ងៃចន្ទ ទី៣១ ខែសីហា ឆ្នាំ២០២០

The Phnom Penh Post

ភ្នំពេញ ប៉ុស្តិ៍

# យើងយកចិត្តទុកដាក់ និងចែករំលែក

**ជូនចំពោះមិត្តរួមជាតិម៉ាឡេស៊ីទាំងអស់**

ថ្ងៃទី៣១ ខែសីហា គឺជាថ្ងៃដែលយើងប្រារព្ធវាបុណ្យជាតិខួបលើកទី៦៣ របស់យើង និងខួបនៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសម៉ាឡេស៊ីនិងព្រះរាជាណាចក្រកម្ពុជា។

សូមយើងរំឭកឡើងវិញនូវថ្ងៃជាប្រវត្តិសាស្ត្រមួយនេះ គឺនៅពេលដែលនាយករដ្ឋមន្ត្រីដំបូងរបស់យើងគឺលោកនាយករដ្ឋមន្ត្រី Tunku Abdul Rahman បានសាទរដោយប្រកាសពាក្យ«Merdeka» ចំនួន៧ដង និងបានអានសេចក្ដីប្រកាសឯករាជ្យឆ្នាំ១៩៥៧ នៅចំពោះមុខប្រជាជនម៉ាឡេស៊ីរាប់ពាន់នាក់។ ក្រៅពីការអបអរសាទរទិវាបុណ្យជាតិរបស់យើង យើងក៏សូមរំឭកដល់អ្នកដែលបានលះបង់ដើម្បីសុវត្ថិភាព និងសុខដុមរមនាសម្រាប់ប្រជាជាតិជាទីស្រឡាញ់របស់យើងផងដែរ។

ការប្រារព្ធទិវាបុណ្យជាតិម៉ាឡេស៊ីក្នុងឆ្នាំនេះត្រូវបានធ្វើឡើងក្រោមប្រធានបទ«Malaysia Cares» ហើយក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ១៩ សារៈសំខាន់នៃការរួបរួមគ្នាគឺសំខាន់ខ្លាំងណាស់។ ទន្ទឹមនឹងការប្រយុទ្ធប្រឆាំងជំងឺរាតត្បាតនេះ យើងត្រូវតែបន្តឆ្ពោះទៅមុខ និងធ្វើការរួមគ្នាដើម្បីអភិវឌ្ឍប្រទេសដោយផ្អែកលើកម្លាំងនៃសាមគ្គីភាពរបស់យើង។

យើងត្រូវការរួបរួម និងសាមគ្គីភាពច្រើនជាងពេលណាៗទាំងអស់។ សូមឱ្យយើងពង្រឹងការតាំងចិត្តរបស់យើង ដើម្បីអាចសម្រេចបាននូវគោលដៅដ៏អស្ចារ្យរបស់យើងទាំងអស់។ ផ្លូវខាងមុខនៅវែងឆ្ងាយ ការឡើងទៅទីខ្ពស់របស់យើងគឺចោតខ្លាំង យើងប្រហែលមិនអាចទៅដល់ទីនោះឆាប់ៗទេ ប៉ុន្តែខ្ញុំសូមសន្យាថា ក្នុងនាមជាក្រុម យើងនឹងទៅដល់ទីនោះនៅថ្ងៃណាមួយ។ យើងអាចហើយយើងនឹងឆ្លងកាត់ឧបសគ្គនេះបាន!



**ឯកឧត្តម** Eldeen Husaini Hohd Hashim **ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា។**

នៅពេលយើងជួបស្ថានភាពធ្ងន់ធ្ងរដូចករណីវិបត្តិជំងឺកូវីដ១៩ យើងត្រូវតែគាំទ្រគ្នាទៅវិញទៅមក ហើយក្រៅពីមិត្តរួមជាតិម៉ាឡេស៊ី យើងក៏មិនភ្លេចសហគមន៍មូលដ្ឋានដែរ។ ខ្ញុំរីករាយណាស់ដែលគំនិតផ្ដួចផ្ដើមកម្មវិធី«យើងយកចិត្តទុកដាក់ និងចែករំលែក» ( We Care, We Share ) របស់ស្ថានទូត គឺយើងបានជួយចែករំលែកដល់ប្រជាជនកម្ពុជាជាច្រើន។ លើសពីនេះទៀត កម្មវិធី«យើងយកចិត្តទុកដាក់ និងចែករំលែក»គឺស្របគ្នាជាមួយប្រធានបទទិវាបុណ្យជាតិក្នុងឆ្នាំនេះ។

ដូច្នេះខ្ញុំមានក្ដីសោមនស្សរីករាយខ្លាំងណាស់ដែលប្រជាជនម៉ាឡេស៊ីជាច្រើនបានចូលរួមជាផ្នែកមួយនៃកម្មវិធីដ៏ប្រពៃនេះ ដើម្បីជួយដល់អ្នកដែលខ្វះខាតខ្លាំង។ យើងក៏បន្តចូលរួមជាមួយមិត្តភក្តិកម្ពុជារបស់យើងតាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការការពារជាតិម៉ាឡេស៊ី និងជួបជុំអតីតនិស្សិតផងដែរ។ ការចូលរួមបែបនេះបានផ្ដល់ឱកាសឲ្យខ្ញុំបានដឹងអំពីភាពជឿនលឿនរបស់អតីតនិស្សិត ខណៈដែលពួកគេក៏ជាសមាជិកផ្លូវការនៃសមាគម «Friends of Malaysia»។ ក្នុងឆ្នាំនេះក៏មានជើងហោះហើរធ្វើមាតុភូមិនិវត្តន៍ជនជាតិម៉ាឡេស៊ីជាង៥០០នាក់ បានវិលត្រឡប់ទៅផ្ទះរបស់ពួកគេវិញដោយសុវត្ថិភាព ដែលរៀបចំដោយក្រុមការងាររបស់ខ្ញុំ។

ប៉ុន្តែវាមិនមែនចុងបញ្ចប់នៃការងាររបស់យើងទេ។ នៅមានការងារជាច្រើនទៀតដែលយើងត្រូវការជួយជ្រោមជ្រែង ហើយយើងនឹងនៅទីនោះជាមួយពួកគេ។ ពេលនេះគឺជាពេលដែលយើងត្រូវបង្ហាញស្មារតីស្នេហាជាតិ មោទនភាពជាតិ និងក្ដីស្រឡាញ់ចំពោះប្រទេសម៉ាឡេស៊ី។ បុគ្គលិករបស់ខ្ញុំនិងរូបខ្ញុំបានដោតទង់ជាតិ ( Jalur Gemilang ) នៅជុំវិញបរិវេណស្ថានទូត ហើយខ្ញុំសូមលើកទឹកចិត្តដល់ជនរួមជាតិម៉ាឡេស៊ីទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជាសូមដោតទង់ជាតិ របស់យើងឲ្យខ្ពស់ត្រដែត!

ទោះបីជាយើងមិនអាចប្រារព្ធព្រឹត្តិការណ៍ដ៏សំខាន់នេះដូចដែលយើងធ្លាប់ធ្វើក្ដី ក៏វាមិនគួរជាហេតុផលដែលមិនឱ្យយើងរីករាយដែរ សូមឲ្យយើងប្រកាន់ខ្ជាប់ និងលើកកម្ពស់ថែមទៀតនូវភាពសុខដុមរមនា និងការស្នេហាជាតិរបស់យើង និងប្រកាន់ខ្ជាប់របៀបវារៈនៃការកសាងប្រទេសជាតិ។

អ្វីដែលធ្វើឱ្យទិវាបុណ្យជាតិម៉ាឡេស៊ីក្នុងឆ្នាំនេះកាន់តែពិសេសនិងរំភើបទៀតនោះគឺប្រជាជនម៉ាឡេស៊ី៦៣នាក់( បញ្ជាក់ពីថ្ងៃកំណើតគម្រប់ខួប៦៣ឆ្នាំរបស់ជាតិយើង ) មកពីគ្រប់មជ្ឈដ្ឋានក្នុងរាជធានីភ្នំពេញនឹងមកជុំគ្នានៅថ្ងៃទី៣០ខែសីហាក្នុងនាមជាប្រជាជាតិមួយនៅលើទឹកដី បរទេសដើម្បីជិះកង់ និងម៉ូតូក្នុងព្រឹត្តិការណ៍« Merdeka Ride» ដើម្បីរំឭកដល់អ្នកដែលបានតស៊ូ និងលះបង់ដើម្បីយើងទាំងអស់គ្នា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់មិត្តរួមជាតិម៉ាឡេស៊ីដែលបានគាំទ្រយ៉ាងពេញទំហឹងដើម្បីធ្វើឲ្យព្រឹត្តិការណ៍នេះទទួលបានជោគជ័យ។

ជាចុងក្រោយ ខ្ញុំក៏សូមជូនពរដល់ប្រជាជនម៉ាឡេស៊ីទាំងអស់នៅក្នុងប្រទេសកម្ពុជា «Selamat Menyambut Hari Kebangsaan»។ សូមចាំថាយើងមានមោទនភាពណាស់ដែលបានហៅប្រទេសម៉ាឡេស៊ីជាផ្ទះរបស់យើង។

អ្វីៗទាំងអស់គឺមកពីសក្ដានុពលនៃការដែលយើងមានវប្បធម៌ចម្រុះ ពហុសាសន៍ ពហុភាសា និងមានម្ហូបអាហារដ៏ឈ្ងុយឆ្ងាញ់ដែលវាបានក្លាយជាផ្នែកមួយដ៏សំខាន់នៃសង្គមរបស់យើង។ សូមឲ្យគ្រប់គ្នាមានសុខសុវត្ថិភាព និងរួមគ្នាធ្វើដំណើរឆ្ពោះទៅរកជ័យជម្នះក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩។

សូមអរគុណ សូមព្រះប្រទានពរដល់អ្នកទាំងអស់គ្នា និងសូមព្រះប្រទានពរ Malaysia Prihatin !

**ឯកឧត្តម** ELDEEN HUSAINI MOHD HASHIM, **ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា។**












ការយកចិត្តទុកដាក់លើអតិថិជន សហគមន៍ និងនិយោជិត ជាស្នូលនៃការធ្វើប្រតិបត្តិការអាជីវកម្មរបស់ពួកយើង គឺជាមូលដ្ឋានគ្រឹះនៃបេសកកម្មរបស់យើង **ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយអរិយភាព។**

ពួកយើងខិតខំធ្វើឲ្យសហគមន៍ មានការរីកចម្រើន លូតលាស់ និងជោគជ័យ។










# នៅក្នុងបេះដូងរបស់សហគមន៍

ដោយត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសហគមន៍ ដែលពួកយើងបានផ្តល់សេវាកម្ម តម្រូវការ និងបទពិសោធន៍នៃការទទួលគុណភាពសេវាកម្មរបស់អតិថិជន គឺជាអាទិភាពរបស់ពួកយើង។ ពួកយើង មានមោទនភាព និងផ្តល់តម្លៃដល់ទំនាក់ទំនង ដែលពួកយើងបានកសាង និងប្រវត្តិដែលពួកយើងបានឆ្លងកាត់ជាមួយគ្នា តាមរយៈគោលជំហរនៃការសហការ ដែលធ្វើឲ្យពួកយើងលូតលាស់ និងរីកចម្រើនជាមួយគ្នា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ និងគាំទ្ររបស់ប្រទេសម៉ាឡេស៊ី។

**អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៣ ទិវាបុណ្យឯករាជ្យជាតិម៉ាឡេស៊ី**

www.maybank2u.com.kh

Maybank

# មិត្តភាពគ្រប់កាលៈទេសៈ ដែលនៅតែបន្តភាពរីកចម្រើន

ភ្ជាប់ជាមួយពិធីអបអរសាទរទិវាបុណ្យជាតិរបស់ប្រទេសម៉ាឡេស៊ីនេះដែរ ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា ឯកឧត្តម Eldeen Husaini Mohd Hashim បានចែករំលែកទស្សនៈរបស់លោកជាមួយកាសែតភ្នំពេញប៉ុស្ដិ៍ ស្ដីអំពីចំណងទាក់ទងដែលកំពុងរីកចម្រើនរវាងប្រទេសទាំង២។



ឯកឧត្តម Eldeen ( ឆ្វេង ) សំណេះសំណាលជាមួយលោកនាយករដ្ឋមន្ត្រីហ៊ុន សែន នៅវិមានសន្តិភាព កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៩។ រូបថត ក្រសួងព័ត៌មាន

**តើវិស័យអ្វីខ្លះដែលលោកនឹងផ្តល់អាទិភាពដើម្បីបង្កើនទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំង២ ?**

អាទិភាពចម្បងមួយរបស់ខ្ញុំគឺត្រូវជួយប្រជាជនម៉ាឡេស៊ីដែលកំពុងរស់នៅកម្ពុជា រួមទាំងជួយដល់ផលប្រយោជន៍អាជីវកម្មរបស់ពួកគេនៅទីនេះ។

ជួយដល់ប្រជាជនម៉ាឡេស៊ីក្នុងការរកស៊ីកាន់តែធំនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងជួយពង្រឹងចំណងមិត្តភាពរបស់យើងជាមួយប្រទេសកម្ពុជា។ អាទិភាពផ្សេងទៀត គឺត្រូវបន្តចូលរួមយ៉ាងជិតស្និទ្ធជាមួយរដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ សមាជិកសភា អាជ្ញាធរមូលដ្ឋាន និងតស្សរជនសំខាន់ៗរបស់ប្រទេសកម្ពុជា ដើម្បីរក្សាកិច្ចសហប្រតិបត្តិការដែលមានស្រាប់របស់យើង និងស្វែងរកផ្នែកផ្សេងទៀតនៃផលប្រយោជន៍ទៅវិញទៅមក ដូចជាទូរគមនាគមន៍ ហិរញ្ញវត្ថុ និងធនាគារ សន្តិសុខអ៊ីនធឺណិត កីឡា និងទេសចរណ៍ជាដើម។

ដោយមើលឃើញពីការរឹតបន្តឹងដោយសាជំងឺកូវីដ១៩ ខ្ញុំមានបំណងរក្សាសម្ទុះទៅមុខដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដូចជាកម្មវិធី zoom ប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដូចជា រៀបចំការជួបជុំ និងព្រឹត្តិការណ៍នានាក្នុងទ្រង់ទ្រាយតូចជាងមុន។

**ប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជាមានទំនាក់ទំនងទ្វេភាគីដ៏រឹងមាំ ប្រទេសទាំង២គឺជាប្រទេសឯករាជ្យ និងជាសមាជិកអាស៊ាន។ តើលោកវាយតម្លៃកម្រិតនៃទំនាក់ទំនងប្រទេសទាំង២រហូតមកដល់ពេលនេះ ដូចជាទំនាក់ទំនងរវាងប្រជាជន និងប្រជាជន និងទស្សនវិស័យពាណិជ្ជកម្ម និងការវិនិយោគយ៉ាងដូចម្ដេច ?**

ដោយសារខ្ញុំបានរស់នៅក្នុងប្រទេសកម្ពុជាជាង១ឆ្នាំមកនេះ ដូច្នេះខ្ញុំអាចសង្ខេបពីទំនាក់ទំនងរវាងប្រទេសទាំង២បាន។ ប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជាបានបង្កើតចំណងមិត្តភាពទ្វេភាគីដ៏ល្អប្រសើររួមគ្នា ហើយឥឡូវនេះយើងមានវេទិកាដ៏រឹងមាំមួយ ដើម្បីបន្តជួយគ្នាឲ្យទទួលបាននូវការរីកចម្រើនថែមទៀត។

ខ្ញុំមានសុទិដ្ឋិនិយម ពីព្រោះបើអ្នកគ្រាន់តែក្រឡេកមើលតួលេខ គឺយើងស្ថិតនៅក្នុងចំណោមវិនិយោគិនកំពូលៗនៅកម្ពុជា ខណៈពាណិជ្ជកម្មទ្វេភាគី និងស្ថិតិផ្សេងទៀតដូចជាចំនួនទេសចរ ត្រូវបានមើលឃើញថាមានការកើនឡើងជាលំដាប់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

បើនិយាយអំពីទំនាក់ទំនងរវាងប្រជាជនវិញ វាច្បាស់ណាស់ថា ប្រជាជនរបស់យើងមានគុណសម្បត្តិដូចគ្នា ដូចជា ការតស៊ូអត់ធ្មត់ និងកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញការងារ។ ហើយយើងក៏បានចែករំលែកប្រវត្តិសាស្ត្រមួយចំនួនផងដែរ។ ទាំងនេះគឺជាហេតុផលមួយចំនួនដែលធ្វើឱ្យប្រជាជនម៉ាឡេស៊ី និងប្រជាជនកម្ពុជាមានទំនាក់ទំនងជាមួយគ្នាយ៉ាងល្អ។

បច្ចុប្បន្នចំណងមិត្តភាពរបស់យើងស្ថិតនៅក្នុងស្ថានភាពដ៏ល្អប្រសើរ ប៉ុន្តែមិនមែនមានន័យថា យើងអាចសម្រាកត្រឹមនេះទេ គឺយើងត្រូវតែមានកម្រិតសហប្រតិបត្តិការឲ្យកាន់តែខ្ពស់ជាងនេះទៀត ដើម្បីឆ្ពោះទៅរកគោលដៅ និងសក្ដានុពលរួមគ្នានៅក្នុងផ្នែកជាច្រើនទៀត។ លើសពីនេះ ជាមួយការរីករាលដាលជំងឺកូវីដ១៩ យើងត្រូវតែធ្វើការឲ្យកាន់តែជិតស្និទ្ធដើម្បីដោះស្រាយបញ្ហាប្រឈមនេះ និងធានាថាសេដ្ឋកិច្ចរបស់យើងនៅតែមានជំហររឹងមាំ។

**តាមទស្សនៈរបស់លោក តើផ្នែកណាខ្លះ ដែលរដ្ឋាភិបាលនៃប្រទេសទាំង២ចាំបាច់ត្រូវកែលម្អ ដើម្បីជួយធ្វើឱ្យទំនាក់ទំនងទ្វេភាគីកាន់តែប្រសើរឡើង ?**

ដូចដែលខ្ញុំបាននិយាយរួចមកហើយ ទំនាក់ទំនងរបស់យើងគឺស្ថិតនៅក្នុងកម្រិតមួយដ៏ប្រសើររួចទៅហើយ ដូច្នេះសម្រាប់ខ្ញុំមិនហៅថាធ្វើឲ្យប្រសើរទេ ប៉ុន្តែយើងត្រូវគិតប្រកបដោយភាពច្នៃប្រឌិត និងធ្វើអ្វីៗបន្ថែមទៀតដើម្បីទាញអត្ថប្រយោជន៍ពីទំនាក់ទំនងដ៏ល្អប្រសើររបស់យើង។ ក្នុងចំណោមនោះ អ្វីដែលយើងត្រូវធ្វើគឺជំរុញការផ្លាស់ប្តូរទស្សនកិច្ចឲ្យកាន់តែច្រើនរវាងមន្ត្រីជាន់ខ្ពស់ និងរដ្ឋមន្ត្រីរវាងប្រទេសទាំង២។

យើងបានបង្កើនសម្ទុះដ៏ល្អនៅក្នុងឆ្នាំ២០១៩ ក្នុងនោះមានដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាលរបស់យើងនៅខែកញ្ញាឆ្នាំមុន ប៉ុន្តែក្រោយមកដោយសារវិបត្តិជំងឺកូវីដ សម្ទុះនោះក៏បានថមថយ។ តាមពិតសម្ទុះនេះត្រូវបានរំពឹងថានឹងកើនឡើងម្តងទៀតនៅចុងឆ្នាំនេះ ជាមួយ ASEM [កិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុប] ប៉ុន្តែដោយសារកូវីដ វាក៏បានផ្លាស់ប្តូរទៀត។

ទោះយ៉ាងណា ខ្ញុំជឿជាក់ថា ពិភពលោកនឹងដោះស្រាយជំងឺរាតត្បាតនេះបាន ហើយសម្ទុះនៃទំនាក់ទំនងទ្វេភាគីរបស់យើងនឹងកើនឡើងខ្លាំងម្តងទៀត។ ទិដ្ឋភាពផ្សេងទៀតដែលខ្ញុំចង់លើកកម្ពស់គឺការផ្សារភ្ជាប់រវាងភ្នាក់ងារសំខាន់ៗរបស់យើង។

ខ្ញុំចង់ឱ្យមានទំនាក់ទំនងកាន់តែជិតស្និទរវាងយោធា ឧទាណ៍ កងកម្លាំងរបស់យើង ភ្នាក់ងារពាណិជ្ជកម្ម និងវិនិយោគ,ទីភ្នាក់ងាររបស់យើងដែលមានឯកទេសក្នុងការផ្លាស់ប្តូរសេដ្ឋកិច្ចវិទ្យាស្ថាននីមួយៗ មានទំនាក់ទំនងជាមួយបរទេស និងទំនាក់ទំនងដែលអាចកើតមានផ្សេងទៀតរវាងប្រជាជន និងស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាល។ នេះជាមូលហេតុដែលខ្ញុំគ្រោងទៅកាន់ខេត្តមួយចំនួនដូចជា ខេត្តព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ និងរតនគិរី ដើម្បីស្វែងយល់អំពីលទ្ធភាពនៃការតភ្ជាប់។

**ទាក់ទងកិច្ចព្រមព្រៀងចៀសវាងការយកពន្ធត្រួតគ្នា តើស្ថានភាពវិវឌ្ឍន៍បែបណាហើយ ?**

កម្ពុជា-ម៉ាឡេស៊ី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចៀសវាងការយកពន្ធត្រួតគ្នា (DTA) នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវការរបស់(អតីត) នាយករដ្ឋមន្ត្រីម៉ាឡេស៊ីឯកឧត្តម Mahathir Mohamad មកកាន់ព្រះរាជាណាចក្រកម្ពុជា។

វាគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងចំណោមនិមិត្តសញ្ញាទាំងនោះដែលបង្ហាញពីការកើនឡើងនូវទំនាក់ទំនងទ្វេភាគីរបស់យើង។ កិច្ចព្រមព្រៀង DTA គឺជាកិច្ចព្រមព្រៀងទ្វេភាគីចាំបាច់បំផុតមួយ។ បទប្បញ្ញត្តិដែលមានចែងនៅក្នុងនោះនឹងជួយជំរុញដល់ការធ្វើពាណិជ្ជកម្មឲ្យកាន់តែច្រើន និងដើម្បីសម្រួលដល់ដំណើរការនៃការបង្កើត និងការធ្វើពាណិជ្ជកម្មរវាងប្រទេសម៉ាឡេស៊ី និងកម្ពុជា។ ចំពោះបញ្ហានៃការផ្តល់សច្ចាប័ន ខ្ញុំបានប្រាប់ដល់អាជ្ញាធរម៉ាឡេស៊ីដែលពាក់ព័ន្ធឱ្យដោះស្រាយបញ្ហានេះឱ្យបានសមស្រប និងឆាប់រហ័ស។

**ពាណិជ្ជកម្មទ្វេភាគីបន្តរីកចម្រើនទៅមុខជាលំដាប់។ តើអ្វីជាកត្តាជំរុញផ្នែកពាណិជ្ជកម្ម ហើយតើការចូលរួមរបស់វិស័យឯកជនបានរួមចំណែកដល់ភាពជោគជ័យនៃកំណើននេះឬទេ ?**

ពាណិជ្ជកម្មរវាងម៉ាឡេស៊ី-កម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះបានបន្តសម្ទុះវិជ្ជមានរបស់ខ្លួន។ ពាណិជ្ជកម្មទ្វេភាគីសរុបសម្រាប់ឆ្នាំ២០១៩ មានចំនួន ៧៦៧,៣ លានដុល្លារ។ នេះគឺជាការកើនឡើង៣៧ភាគរយធៀបនឹងឆ្នាំមុន។ បើសិនគ្មានការចូលរួមយ៉ាងសកម្មពីវិស័យឯកជនរបស់យើងទេ យើងប្រាកដជាមិនអាចឈានដល់ចំណុចនេះទេ។ រដ្ឋាភិបាលទាំង២របស់យើងបានធ្វើប្រកបដោយតម្លាភាព ដោយជួយសម្របសម្រួលជំរុញ និងលើកទឹកចិត្តដល់ការបង្កើតអាជីវកម្ម ប៉ុន្តែអ្នកជំនួញរបស់យើងដែលបានធ្វើឱ្យកិច្ចព្រមព្រៀងជំនួញកើតឡើង។

សរុបសេចក្ដីមក ស្ថានភាពទំនាក់ទំនងពាណិជ្ជកម្មដ៏ល្អប្រសើររបស់យើង នឹងមិនអាចធ្វើទៅបាននោះទេបើគ្មានការប្ដេជ្ញាចិត្ត និងការលះបង់ទាំងពីវិស័យឯកជន និងសាធារណៈ។ ទោះយ៉ាងណា ទំហំពាណិជ្ជកម្មគិតចាប់ពីខែមករា ដល់ខែមិថុនាឆ្នាំនេះបានថយចុះ៤៦ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។ ការធ្លាក់ចុះតួលេខក្នុងឆ្នាំនេះគឺដោយសារបញ្ហាជំងឺកូវីដ១៩។ ប្រសិនបើមិនមានបញ្ហាជំងឺកូវីដទេ នោះទំនាក់ទំនងពាណិជ្ជកម្មរបស់យើងប្រហែលបន្តកើនឡើងខ្លាំងថែមទៀត។ នេះហើយជាមូលហេតុដែលខ្ញុំជឿជាក់ថា តួលេខរបស់យើងនឹងកើនឡើងម្តងទៀតនៅឆ្នាំ២០២១ ឬក៏ឆាប់ជាងនេះនៅពេលដែលជំងឺរាតត្បាតមួយនេះត្រូវបានបញ្ចប់។

**ចុះចំពោះវិស័យទេសចរណ៍វិញ ?**

ទាក់ទងនឹងវិស័យទេសចរណ៍ទ្វេភាគី គឺមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចទេសចរណ៍រវាងប្រទេសយើងទាំង២មុនពេលកូវីដផ្ទុះឡើង ប៉ុន្តែជាថ្មីម្តងទៀតតួលេខឆ្នាំនេះមានការថយចុះគួរឱ្យកត់សម្គាល់ គឺដោយសារតែជំងឺនេះ។ ដូចដែលអ្នកបានដឹងហើយថា វិស័យទេសចរណ៍គឺជាវិស័យមួយក្នុងចំណោមវិស័យដែលរងគ្រោះខ្លាំងបំផុតសម្រាប់ប្រទេសជាច្រើន។ ទោះយ៉ាងណា នៅពេលកូវីដបាត់ទៅវិញ ខ្ញុំមើលឃើញថានឹងមានការកើនឡើងនៃចំនួនផ្លាស់ប្តូរទេសចររវាងប្រទេសម៉ាឡេស៊ី និងកម្ពុជា ដោយសារមានតម្រូវការជាច្រើន ប៉ុន្តែវាត្រូវបានផ្អាកដោយសារបញ្ហាកូវីដ។

ព័ត៌មានលម្អិតអានតទៅគេហទំព័រ
WWW.POSTKHMER.COM

# សម្លឹងទៅរកភាពជោគជ័យក្នុងរយៈពេលវែង

ប្រធានក្រុមប្រឹក្សាធុរកិច្ចម៉ាឡេស៊ីប្រចាំកម្ពុជា ( MBCC ) លោក Teh Sing ដែលបានមកកាន់ទីក្រុងភ្នំពេញតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០នោះ បានមើលឃើញការប្រែប្រួលរបស់កម្ពុជាក្រោយភាពរីកវរនៅក្នុងប្រទេស រហូតបានក្លាយជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំមួយនៅក្នុងតំបន់អាស៊ាន។ នៅក្នុងបទសម្ភាសជាមួយកាសែតភ្នំពេញប៉ុស្ដិ៍ អ្នកជំនួញជើងចាស់រូបនេះ បានចែករំលែកដំណើរដ៏វែងឆ្ងាយអំពីការរួមចំណែករបស់ម៉ាឡេស៊ីចំពោះសេដ្ឋកិច្ចកម្ពុជា។



**លោក** Teh Sing **ប្រធានក្រុមប្រឹក្សាធុរកិច្ចម៉ាឡេស៊ីប្រចាំកម្ពុជា។**

**តើ** MBCC **បានចូលរួមចំណែកដូចម្ដេចខ្លះក្នុងការអភិវឌ្ឍវិស័យធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ?**

MBCC ប្រតិបត្តិការជាសមាគមដែលមិនស្វែងរកប្រាក់ចំណេញ និងមិនប្រកាន់និន្នាការនយោបាយ។ គោលបំណងចម្បងរបស់យើងគឺលើកកម្ពស់ និងលើកទឹកចិត្តដល់ធុរកិច្ចម៉ាឡេស៊ី ឲ្យបង្កើត និងរក្សាអាជីវកម្ម ការគ្រប់គ្រង និងការអនុវត្តវិជ្ជាជីវៈឲ្យមានស្តង់ដាខ្ពស់បំផុត ដើម្បីលើកកម្ពស់មុខមាត់ប្រទេសម៉ាឡេស៊ី។

លើសពីនេះ យើងផ្ដល់នូវវេទិកាសម្រាប់ការប្រជុំ ការពិភាក្សាប្រចាំខែសំរាប់ធុរកិច្ចម៉ាឡេស៊ី និងបុគ្គលិករដ្ឋាភិបាលនៅកម្ពុជា។ MBCC នៅតែបន្តលើកទឹកចិត្តដល់ការវិនិយោគរបស់ម៉ាឡេស៊ីនៅកម្ពុជា និងពង្រឹងទំនាក់ទំនងល្អជាមួយសហគមន៍ធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**តើស្ថានភាពអាជីវកម្មបានផ្លាស់ប្ដូរយ៉ាងដូចម្ដេចនៅក្នុងប្រទេសកម្ពុជាចាប់តាំងពី** MBCC **បង្កើតឡើង ? សូមលោករៀបរាប់អំពីប្រវត្តិខ្លះៗ។**

ទិដ្ឋភាពអាជីវកម្មបានរីកចម្រើនជាលំដាប់គិតចាប់តាំងពីឆ្នាំ១៩៩៣។ ឧទារណ៍១ គឺអាជីវកម្ម ផលិតស្រាបៀរ។ នៅឆ្នាំ១៩៩៣ ក្រុមហ៊ុន Cambrew Limited គឺជាក្រុមហ៊ុនម៉ាឡេស៊ីដែលដំណើរការក្រុមហ៊ុនផលិតស្រាបៀរតែ១គត់នៅកម្ពុជា។ សព្វថ្ងៃមានក្រុមហ៊ុនផលិតស្រាបៀរច្រើនជាង៦រួចហើយ។ ឧទាណ៍១ទៀតគឺឧស្សាហកម្មធនាគារ។ នៅក្នុងឆ្នាំ១៩៩៣ ធនាគារពាណិជ្ជមានតិចជាង១០ ប៉ុន្តែសព្វថ្ងៃធនាគារពាណិជ្ជមានចំនួន៥១។

**តាមការប៉ាន់ស្មាន បច្ចុប្បន្នក្រុមហ៊ុនម៉ាឡេស៊ីទាំងធំ និងតូចប្រមាណ៨០០ កំពុងប្រតិបត្តិការនៅកម្ពុជា ដោយមានការគាំទ្រពីពលរដ្ឋម៉ាឡេស៊ីប្រមាណ៣ ០០០នាក់ដែលរស់នៅទីនេះ។ តើអ្វីដែលជំរុញក្រុមហ៊ុនម៉ាឡេស៊ីទាំងនោះឲ្យមកបណ្ដាក់ទុនរកស៊ីនៅកម្ពុជា ?**

វាបានចាប់ផ្ដើមជាមួយអតីតនាយករដ្ឋមន្ត្រីម៉ាឡេស៊ីរបស់យើងគឺលោក Tun Mahathir Mohamad ដែលបានណែនាំគោលនយោបាយវិបុលភាពអ្នកជិតខាង ( Prosper thy neighbours policy ) នៅពេលដែលលោកបានដឹកនាំវិនិយោគិនម៉ាឡេស៊ី១ក្រុមដំបូងគេមកកាន់ប្រទេសកម្ពុជា។ បន្ថែមជាមួយនឹងគោលនយោបាយគាំទ្រអាជីវកម្មរបស់រដ្ឋាភិបាលកម្ពុជា អាជីវកម្មថ្មីៗរបស់ម៉ាឡេស៊ីជាច្រើនក៏ត្រូវបានទាក់ទាញឱ្យមកវិនិយោគនៅកម្ពុជា។

**យុវជនម៉ាឡេស៊ីជំនាន់ថ្មីកំពុងចូលទៅក្នុងយុគអាជីវកម្មថ្មី រាប់ចាប់ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបច្ចេកវិទ្យាឌីជីថល រហូតដល់សេវាកម្មវិជ្ជាជីវៈ។ តើលោកមើលឃើញនិន្នាការដែលកំពុងកើនឡើងនេះយ៉ាងដូចម្ដេច ?**

ប្រាកដណាស់គឺការរីកចម្រើនកាន់តែខ្លាំង។

**ប្រជាជនម៉ាឡេស៊ីជាច្រើនកំពុងកាន់មុខតំណែងកំពូលៗនៅក្នុងក្រុមហ៊ុននៅកម្ពុជា និងក្រុមហ៊ុនអន្តរជាតិ ជាពិសេសនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ? តើប្រជាជនម៉ាឡេស៊ីកំពុងនាំចេញជំនាញវិជ្ជាជីវៈរបស់ពួកគេឬ ?**

ទាក់ទងវិស័យធនាគារ និងហិរញ្ញវត្ថុ ធនាគារកម្ពុជាសាធារណៈ គឺជាធនាគារម៉ាឡេស៊ីដំបូងគេដែលប្រតិបត្តិការនៅកម្ពុជាក្នុងឆ្នាំ១៩៩២ ហើយធនាគារនេះចាប់ផ្ដើមដោយមានសាខាតែ១ប៉ុណ្ណោះ ប៉ុន្តែសព្វថ្ងៃធនាគារនេះមាន៣១សាខា ដែលដឹកនាំដោយប្រជាជនកម្ពុជា។ នេះគឺជាឧទាហរណ៍ដ៏ល្អមួយនៃការនាំចេញជំនាញវិជ្ជាជីវៈរបស់ម៉ាឡេស៊ី។

**តើលោកអាចចែករំលែកអំពីការវិវឌ្ឍនៃទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-ម៉ាឡេស៊ី ជាពិសេសនៅក្នុងកម្រិតវិស័យឯកជនបានដែរឬទេ ?**

ម៉ាឡេស៊ីគឺជាអ្នកវិនិយោគធំជាងគេនៅទីនេះអស់រយៈពេលជាង១ទសវត្សរ៍ រហូតដល់ចិនចូលមកជំនួសតំណែងនេះ។ ធុរកិច្ចម៉ាឡេស៊ីត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជាក៏ដូចជាសហគមន៍ធុរកិច្ចកម្ពុជានៅទីនេះ។ ទំនាក់ទំនងពាណិជ្ជកម្មដ៏ល្អរវាងប្រទេសទាំង២កាន់តែរីកចម្រើនល្អប្រសើរឡើងជាលំដាប់ ហើយបច្ចុប្បន្នយើងមានឯកអគ្គរាជទូតម៉ាឡេស៊ីដ៏សកម្ម ( ឯកឧត្តម Eldeen Husaini ) ដែលកំពុងខិតខំប្រឹងប្រែងពង្រឹងទំនាក់ទំនងនេះ។

ព័ត៌មានលម្អិតអានតទៅគេហទំព័រ
WWW.POSTKHMER.COM



# លំហូរពាណិជ្ជកម្ម



**៧៦៧**
លានដុល្លារ
ពាណិជ្ជកម្មសរុប(២០១៩)

**៦០០**
លានដុល្លារ
ម៉ាឡេស៊ីនាំចេញ(២០១៩)

## ទំនិញនាំចេញទៅកម្ពុជា ២០១៩



ផលិតផលប្រេង
**២២៥** លានដុល្លារ



វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង
**៨៨** លានដុល្លារ



អាហារកែច្នៃ
**៤៩** លានដុល្លារ



គីមី និងផលិតផលគីមី
**៣៦** លានដុល្លារ



ឧបករណ៍ដឹកជញ្ជូន
**៣១** លានដុល្លារ

## ទំនិញនាំចេញទៅម៉ាឡេស៊ី ២០១៩



វាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង
**៨០** លានដុល្លារ



ផលិតផលផលិតកម្មផ្សេងៗ
**៩** លានដុល្លារ



ដូងប្រេង
**៣១** លានដុល្លារ



កៅស៊ូធម្មជាតិ
**១៤** លានដុល្លារ



ផលិតផលកសិកម្ម
**៣១** លានដុល្លារ

ប្រភព: Multiple agencies



ម៉ាឡេស៊ីបានបង្កើតចំណងការទូតជាមួយកម្ពុជា នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៥៧។




ម្ហូប ម៉ា ម៉ា គឺជាភោជនីយដ្ឋានម៉ាឡេស៊ីចំណាស់ជាងគេនៅកម្ពុជាចាប់ផ្តើមនៅទសវត្សរ៍១៩៩០។

ធនាគារកម្ពុជាសាធារណៈគឺជាធនាគារម៉ាឡេស៊ីដំបូងគេដែលប្រតិបត្តិការនៅកម្ពុជាក្នុងឆ្នាំ១៩៩២។



Malaysian Business Council of Cambodia

ក្រុមប្រឹក្សាធុរកិច្ចម៉ាឡេស៊ីនៅកម្ពុជា ( MBCC ) បង្កើតឡើងនៅ ខែកុម្ភៈ ឆ្នាំ១៩៩២។


អបអរសាទរទិវាបុណ្យជាតិ
ម៉ាឡេស៊ីខួបលើកទី៦៣
ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០
ពីគណៈគ្រប់គ្រង និងបុគ្គលិកនៃ
mpa
MPA INTERNATIONAL LTD
Our Security Services: Physical Guarding, Electronic Security Systems, Executive Protection, Cash-In-Transit, Armed Vehicle Transport, Aviation Security, Supply Chain Security.
Other Services: Manpower Supply, Cleaning Services.


ជូនពរប្រជាជនម៉ាឡេស៊ីទាំងអស់
ក្នុងឱកាសទិវាបុណ្យជាតិ
ខួបលើកទី ៦៣
ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០
ពីគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់នៃ
CAMBODIAN PUBLIC BANK
(A wholly-owned Subsidiary of Public Bank Malaysia)
CAMPU LONPAC INSURANCE
CAMPU SECURITIES


អបអរសាទរ
ទិវាបុណ្យជាតិម៉ាឡេស៊ី
២០២០
ផ្ញើប្រាក់ទៅប្រទេសម៉ាឡេស៊ី
ក្នុងតម្លៃសេវាទាបបំផុតត្រឹមតែ ៥ដុល្លារ ប៉ុណ្ណោះ
ស្កេនទីនេះដើម្បីទាញយក
កម្មវិធីស្មាតហ្វូនវីង
ធនាគារឯកទេសវីង
023 999 989 | 012 999 489
www.wingmoney.com
12 years ANNIVERSARY
Wing

# ក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីម៉ាឡេស៊ីកំពុងបង្កើនថាមពលអគ្គិសនីនៅកម្ពុជា

ក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីដែលបានចុះបញ្ជីបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូង គឺក្រុមហ៊ុន Pestech (Cambodia) កំពុងអនុវត្តគំនិតផ្ដួចផ្ដើមបច្ចេកវិទ្យាបញ្ជូនថាមពលអគ្គិសនីរបស់ខ្លួន។

អស់រយៈពេល ១ទសវត្សរ៍កន្លងមកនេះ ក្រុមហ៊ុនកំពុងផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ជនបទ ជួយពង្រឹងអ្នកមានទេពកោសល្យក្នុងស្រុកអំពីឧស្សាហកម្មថាមពលអគ្គិសនី និងរួមចំណែកដល់វិស័យអគ្គិសនីនៅក្នុងស្រុក។



**លោក** Lim Pay Chuan **នាយកប្រតិបត្តិនៃក្រុមហ៊ុន** Pestech International។

លោក Lim Pay Chuan នាយកប្រតិបត្តិនៃក្រុមហ៊ុន Pestech International បានឲ្យភ្នំពេញប៉ុស្ដិ៍ដឹងថា៖ «ធនធានមនុស្សរបស់ក្រុមហ៊ុន Pestech ជាង៦០ភាគរយ គឺជាជនជាតិខ្មែរដែលរួមមានទាំងផ្នែករចនាប្លង់ វិស្វកម្ម និងគណនេយ្យ»។

បច្ចុប្បន្នក្រុមហ៊ុនបានចូលរួមក្នុងការកសាងបណ្ដាញបញ្ជូនអគ្គិសនីប្រមាណ ៨៥០គីឡូម៉ែត្រ និងអនុស្ថានីយចំនួន៥ រួមទាំងប្រព័ន្ធបញ្ជូនអគ្គិសនី៥០០គីឡូវ៉ុល ពីខេត្តព្រះសីហនុ ទៅឃុំបែកចានក្នុងខេត្តកណ្ដាល។

ក្រៅពីគម្រោងទាំងអស់នេះមានខ្សែបណ្ដាញបញ្ជូនថាមពលប្រវែង ៥១៥គីឡូម៉ែត្រ ត្រូវបានបញ្ចប់ដោយជោគជ័យ។

គម្រោងទាំងនេះ គឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍បណ្ដាញថាមពលអគ្គិសនីជាតិនៅទូទាំងប្រទេស ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់អគ្គិសនីសម្រាប់តម្រូវការនៅតំបន់ជនបទ និងទីប្រជុំជន រួមទាំងការគាំទ្រដល់សេចក្ដីត្រូវការដើម្បីឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងពាណិជ្ជកម្ម តាមរយៈការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជននៅតាមជនបទ។

លោក Lim ថ្លែងថា៖«ឧទាហរណ៍ដ៏ល្អមួយគឺការនាំមកនូវការផ្គត់ផ្គង់ថាមពលអគ្គិសនីដែលអាចទុកចិត្តបាន និងមានស្ថិរភាពទៅខេត្តកំពង់ចាម និងខេត្តក្រចេះដែលសកម្មភាពអាជីវកម្មជាច្រើនត្រូវបានបង្កើតឡើង ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានហិរញ្ញវត្ថុ»។

ក្រុមហ៊ុន Pestech ត្រូវបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជាកាលពីខែសីហា ហើយថវិកាដែលប្រមូលបាននឹងយកទៅប្រើប្រាស់សម្រាប់គម្រោងដែលកំពុងបន្ត និងជាមូលធនបំពេញការងារ។

លោក Lim មានប្រសាសន៍ថា៖ «វិស័យថាមពលកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សដោយផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការជាចាំបាច់។ យើងក៏បានគាំទ្រដល់សុខុមាលភាពរបស់សហគមន៍ដែលយើងបានធ្វើការជាប្រចាំ។ យើងបានផ្ដល់ការព្យាបាលជំងឺដោយឥតគិតថ្លៃ ជួសជុលសាលារៀន កម្មវិធីអភិវឌ្ឍន៍យុវជន យុទ្ធនាការរៃអង្គាសថវិកាប្រចាំឆ្នាំរបស់កាកបាទក្រហម និងកម្មវិធីទទួលខុសត្រូវសង្គមជាច្រើនទៀតនៅក្នុងប្រទេសកម្ពុជា»។



ទំហំទ្រព្យសកម្មរបស់ក្រុមហ៊ុនកសាងហេដ្ឋារចនាសម្ព័ន្ធថាមពលមួយនេះបានកើនឡើងពី ៤០០ ០០០ ដុល្លារ នៅក្នុងឆ្នាំ២០១០ ដល់១៤លានដុល្លារអាមេរិកកាលពីឆ្នាំមុន។

លោក Lim បានបញ្ជាក់ទៀតថា៖ «ប្រាកដណាស់ថាប្រទេសកម្ពុជាកំពុងប្រើប្រាស់ថាមពលអគ្គិសនីកើនឡើង ស្របតាមកំណើន GDP ប្រកបដោយចីរភាព អស់រយៈប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ»។

ប្រភពពី ADB បានបង្ហាញថាតម្រូវការប្រើប្រាស់អគ្គិសនីសរុបនៅក្នុងឆ្នាំ ២០១៦ មានចំនួន ៤០០ គីឡូវ៉ាត់ម៉ោងក្នុងមនុស្សម្នាក់ ដោយកើនឡើងពី២៧០គីឡូវ៉ាត់ម៉ោងកាលពីក្នុងឆ្នាំ២០១៤៕ ■




SCIA
Singapore Cambodia International Academy
K12 Education
Pre-University Education
Enrichment Programmes
Workshops and Seminars
"On behalf of the SCIA Management and SIM Group, I wish all Malaysians and their families happiness, peace and prosperity. My team at SCIA will continue to strengthen our relationship with our parents and corporate partners, so as to better serve the community."
Selamat Hari Merdeka!
SCIA Campus
Located within One Park Phnom Penh City Center
Tan Wee Pin
Managing Director, SCIA
English: (855) 61 777 818
Khmer: (855) 77 678 849
Chinese: (855) 61 777 817
For more information
www.scia.com.kh
Email
enquiry@scia.edu.kh
Follow Us
Singapore Cambodia International Academy
WeChat ID
SCIA_Education
Address
One Park, Phnom Penh City Center, No. 58, Street R8, Sangkat Srah Chak, Khan Doun Penh, Phnom Penh, Cambodia
Singapore (Cambodia) International Academy Co., Ltd.
A Member of Singapore Institute of Management (SIM) Group
Pursue endless possibilities


MERDEKA!
MERDEKA!
MERDEKA!
ជូនពរប្រជាជនម៉ាឡេស៊ីទាំងអស់នៅក្នុងប្រទេសកម្ពុជា
ក្នុងឱកាសទិវាបុណ្យជាតិ
ខួបលើកទី 63
Hard Rock CAFE
Hard Rock CAFE
CAMBODIA

# ព្រឹត្តិការណ៍នានាបង្ហាញពីការយកចិត្តទុកដាក់របស់ម៉ាឡេស៊ី







ដោយបង្ហាញអំពីការយកចិត្តទុកដាក់របស់ខ្លួន ស្ថានទូតម៉ាឡេស៊ីប្រចាំទីក្រុងភ្នំពេញបានរៀបចំព្រឹត្តិការណ៍ផ្សេងៗ និងមានសកម្មភាពជាច្រើន។ មន្ត្រីស្ថានទូតបានចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពទាំងនោះ រាប់ចាប់ពីសកម្មភាពផ្តល់ជំនួយសប្បុរសធម៌នៅក្រោមគំនិតផ្តួចផ្តើម«យើងយកចិត្តទុកដាក់ និងចែករំលែក» និងការផ្ញើមាតុភូមិនិវត្តន៍ជនជាតិម៉ាឡេស៊ីដែលជាប់គាំងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលផ្ទុះឡើងជំងឺកូវីដ១៩ ការរៀបចំព្រឹត្តិការណ៍កីឡា និងការប្រារព្ធពិធីបុណ្យរបស់ម៉ាឡេស៊ីជាច្រើនទៀត៕















SELAMAT
HARI MERDEKA
AUGUST 31
The 63rd Hari Merdeka is different from those of previous years due to the ongoing COVID-19 pandemic. During this challenging time, we at Smart Axiata, as a part of Axiata Group Berhad, would like to send a message of solidarity and support to our Malaysian friends in Cambodia on this occasion as we stand strong together against the coronavirus.
1M USD COVID-19 RELIEF FUND
At Smart, we will continue creating positive impacts to address issues arising from the COVID-19 crisis through our 1 Million USD COVID-19 Relief Fund.
Thus far, 9 entities have been granted funding to set up their projects which focus on ICT for education, personal hygiene, crisis management and social distancing.
Institut Pasteur du Cambodge
VEAC
GLOBE MEDIA ASIA
Open Institute
BAYON
Save the Children
east meets west
IMPACT HUB
friends international
Smart Axiata's Fund is still accepting applications.
For more information, please contact us at sustainability@smart.com.kh.
Smart
smart.com.kh
an axiata company